ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៦៦៩......សហវ.ប្រក

# ប្រកាសរួម
## ស្តីពី
## ការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសអន្តរក្រសួងលេខ ៣៧៧ ប.ក/ប្រក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រាក់ឈ្នួលយោងប្រចាំថ្ងៃ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងយុត្តិធម៌
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .–**

អនុញ្ញាតឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុវត្តការប្រមូលចំណូលពីការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .–**

កម្រិតទឹកប្រាក់នៃការពិន័យចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ ត្រូវបានកំណត់ផ្អែកទៅតាមស្ថានទម្ងន់នៃអំពើល្មើស និងចែកចេញជាពីរកម្រិត គឺកម្រិតទឹកប្រាក់ពិន័យស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្រិតទឹកប្រាក់ពិន័យអនុលោមតាមការសម្រេចរបស់សាលាជម្រះក្តី ដូចមានចែងលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

ចំនួនទឹកប្រាក់ដែលត្រូវពិន័យទៅតាមករណីប្រព្រឹត្តល្មើសនីមួយៗ ត្រូវបានគណនាផ្អែកតាមប្រាក់ឈ្នួលយោងប្រចាំថ្ងៃ និងចំនួនថ្ងៃដែលត្រូវទទួលរងការពិន័យ។ ចំពោះប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ត្រូវអនុលោមតាមការកំណត់នៃប្រកាសអន្តរក្រសួងលេខ ៣៧៧ ប.ក/ប្រក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រាក់ឈ្នួលយោងប្រចាំថ្ងៃ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងយុត្តិធម៌ ឬ ផ្អែកតាមប្រកាសអន្តរក្រសួងរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងយុត្តិធម៌ ស្តីពីការកែសម្រួលប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ក្នុងករណីមានការកែសម្រួលប្រកាសអន្តរក្រសួងលេខ ៣៧៧ ប.ក/ប្រក ខាងលើនេះ។

**ប្រការ៣ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបិទផ្សាយជាសាធារណៈនូវប្រកាសរួម ព្រមទាំងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៤ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវកំណត់អំពីនីតិវិធីសម្រាប់អនុវត្តការពិន័យជាប្រាក់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសត្រូវទុករយៈពេលមួយសមស្របសម្រាប់ការបង់ប្រាក់ពិន័យចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ។

**ប្រការ៥ .-**

ការបែងចែកភារកិច្ចលើការគ្រប់គ្រង និងការប្រមូលចំណូល រវាងរដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្ញើប្រកាសនេះចំនួនមួយច្បាប់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

**ប្រការ៦ .-**

រាល់ការប្រមូល ឬ ការទទួលប្រាក់ចំណូលជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ ដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៧ .-**

រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន, បង់ប្រាក់ចំណូល និងផ្ញើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៨ .-**

ប្រាក់ចំណូលដែលប្រមូលបានពីការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ ត្រូវបានបែងចែកដូចខាងក្រោម ÷

១- ការពិន័យជាប្រាក់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ ចំនួន ៣០% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៦៩% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ ចំនួន ៣០% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ចំនួន ៦៩% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

២- ការពិន័យជាប្រាក់ អនុលោមតាមការសម្រេចរបស់សាលាជម្រះក្តី

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ ចំនួន ២៦% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៤៩% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តសរុបជូនសាលាជម្រះក្តីពាក់ព័ន្ធ ចំនួន ២៤% នៃប្រាក់ពិន័យដែលប្រមូលបាន
-ផ្តល់រង្វាន់លើកទឹកចិត្ត ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ ចំនួន ២៦% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ចំនួន ៤៩% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តសរុបជូនសាលាជម្រះក្តីពាក់ព័ន្ធ ចំនួន ២៤% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

**ប្រការ៩ .–**

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្តសរុប ដោយដកយកពីប្រាក់ពិន័យដែលប្រមូលបានរៀងៗខ្លួន ដើម្បីចាត់ចែងបើកផ្តល់ជូនអង្គភាពគោលដៅដែលបានកំណត់នៅក្នុងប្រការ ៨ នៃប្រកាសរួមនេះ។ ការកាត់ទុកប្រាក់ចំណូលនេះ ត្រូវបានចាត់ទុកថារដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត បានបុរេប្រទានថវិកាពីចំណូលថវិកាជាតិ។

**ប្រការ១០ .-**

រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវគ្រោងចំណូលសរុប និងចំណាយសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រាក់រង្វាន់របស់សាលាជម្រះក្តី។ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងប្រាក់រង្វាន់របស់សាលាជម្រះក្តី។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីចំណូលថវិកាជាតិ(រង្វាន់ដែលបានកាត់ទុក)។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែរ។

**ប្រការ១១ .-**

ការគណនា ការកាត់ទុក ការប្រើប្រាស់ និងការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុលោមតាមការកំណត់នៃសារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ។

**ប្រការ១២ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

របាយការណ៍ស្តីពីការអនុវត្តចំណូលពីការពិន័យជាប្រាក់ ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ ជាផ្នែកមួយនៃរបាយការណ៍រួមស្តីពីការអនុវត្តចំណូលរបស់រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត។

**ប្រការ១៣ .-**

កម្រិតទឹកប្រាក់នៃការពិន័យចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ និងការផ្តល់អត្រាប្រាក់រង្វាន់លើកទឹកចិត្តជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចកែប្រែបានតាមការចាំបាច់ ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងសាលាជម្រះក្តីគ្រប់ថ្នាក់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

រដ្ឋមន្ត្រី
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**អ៊ិត សំហេង**

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសរួមលេខ ៦៥៩ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៦

ស្តីពីការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ

| ល.រ | បរិយាយ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល) | ការពិន័យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ការពិន័យអនុលោមតាមការសម្រេចរបស់សាលាជម្រះក្តី | |
|---|---|---|---|---|---|---|
| | | | ចំនួនថ្ងៃវងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) | ចំនួនថ្ងៃវងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) |
| | | 1 | 2 | 3 = 1 x 2 | 4 | 5 = 1 x 4 |
| 1 | ការរើសអើង (មាត្រា ១២) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 2 | គ្មានច្បាប់ស្តីពីការងារតម្កល់នៅសហគ្រាសគ្រឹះស្ថាន (មាត្រា ១៤) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 3 | ការងារដោយបង្ខំ (មាត្រា ១៥) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 4 | ការជួលមនុស្សឱ្យធ្វើការងារដើម្បីកាត់ប្រាក់ជំពាក់ (មាត្រា ១៦) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 5 | គ្មានសេចក្តីប្រកាសជូនដំណឹងបើក ឬបិទសហគ្រាសគ្រឹះស្ថាន (មាត្រា ១៧ និង ១៨) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 6 | គ្មានសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន (មាត្រា ២០) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 7 | គ្មានសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក (មាត្រា ២១) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 8 | គ្មានបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស (មាត្រា ២២) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 9 | មិនបានរៀបចំបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសក្នុងរយៈពេលបីខែបន្ទាប់ពីថ្ងៃបើកសហគ្រាស ឬបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសដែលដាក់ឱ្យប្រើប្រាស់គ្មានទិដ្ឋាការរបស់អធិការការងារ (មាត្រា ២៤) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |

| ល.រ | បរិយាយ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល) | ការពិន័យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ការពិន័យ[illegible]តាម ការសម្រេចរបស់សាលាជម្រះក្តី | |
|---|---|---|---|---|---|---|
| | | | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) |
| | | 1 | 2 | 3 = 1 x 2 | 4 | 5 = 1 x 4 |
| 10 | និយោជកពិន័យជាប្រាក់ចំពោះកម្មករនិយោជិតដោយកាត់បន្ថយប្រាក់ឈ្នួលដែលត្រូវទទួលបានជាធម្មតា (មាត្រា ២៨) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 11 | មិនបានបិទផ្សាយបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស នៅទីកន្លែងដែលកម្មករងាយមើល (មាត្រា ២៩) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 12 | កែប្រែបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសដោយមិនគោរពតាមលិខិតបទដ្ឋានគតិយុត្តិរបស់ក្រសួងការងារ និងវិជ្ជាជីវៈ ដែលនៅជាធរមាន (មាត្រា ៣០) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 13 | ការប្រើប្រាស់សៀវភៅការងារកម្មករខ្មែរខុសគោលការណ៍ច្បាប់ (មាត្រា ៣៤) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 14 | មិនចុះទិដ្ឋាការចូល ឬឈប់ធ្វើការនៅក្នុងសៀវភៅការងារកម្មករនិយោជិតខ្មែរ (មាត្រា ៣៧) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 15 | គ្មានសៀវភៅបើកប្រាក់ (មាត្រា ៣៩) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 16 | អាគារបដ្ឋានដែលបើកលក់ មិនបានអនុវត្តតាមគ្រប់លក្ខខណ្ឌដែលបានកំណត់ (មាត្រា ៤២) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 17 | ការបើកអាគារបដ្ឋាន មិនគោរពតាមប្រកាសរបស់ក្រសួងក.ប (មាត្រា ៤៣) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 18 | និយោជកពុំមានកិច្ចធានាជាប្រាក់កាស ឬជាប័ណ្ណសិទ្ធិណាមួយក្នុងការចុះកិច្ចសន្យាការងារ ឬការរក្សាកិច្ចសន្យាការងារ (មាត្រា ៤៤) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 19 | គ្មានកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ (មាត្រា ៤៥) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |

| ល.រ | បរិយាយ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល) | ការពិន័យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ការពិន័យអន្តរការណ៍តាមការសម្រេចរបស់សាលាឧទ្ធរណ៍ | |
|---|---|---|---|---|---|---|
| | | | ចំនួនថ្ងៃវងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) | ចំនួនថ្ងៃវងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) |
| | | 1 | 2 | 3 = 1 x 2 | 4 | 5 = 1 x 4 |
| 20 | កេងប្រយោជន៍ដោយការិយភារី (មាត្រា ៤៦) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 21 | ការិយភារីមិនបានបិទប្រកាសឋានៈ នាម អាសយដ្ឋាននៃសហគ្រិន (មាត្រា ៤៩) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 22 | សហគ្រិនមិនបានបញ្ជូនបញ្ជីរាយនាមការិយភារីដែលបានចុះកិច្ចសន្យាជាមួយទៅអធិការដ្ឋានការងារ (មាត្រា ៥០) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 23 | គ្មានការហ្វឹកហ្វឺនកូនជាង ឬមានកូនជាងមិនគ្រប់ចំនួនតាមអត្រាកំណត់ (មាត្រា ៥៧) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 24 | គ្មានការបំពេញកាតព្វកិច្ចរបស់គ្រូក្នុងការបង្រៀន សម្រួលដល់កូនជាង និងពុំមានចេញវិញ្ញាបនបត្រ (មាត្រា ៥៩) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 25 | អនុវត្តមិនត្រឹមត្រូវតាមនីតិវិធីនៃការព្យួរកិច្ចសន្យាការងារ (មាត្រា ៧២) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 26 | មិនព្រមចេញវិញ្ញាបនបត្របញ្ជាក់ការងារនៅពេលផ្តាច់កិច្ចសន្យាការងារ (មាត្រា ៩៣) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 27 | ការបញ្ឈប់ពីការងាររួមគ្នាមិនប្រតិបត្តិតាមនីតិវិធីជាធរមាន (មាត្រា ៩៥) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 28 | ផ្តល់ប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតមិនបានត្រឹមត្រូវ (មាត្រា ១០៤) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 29 | ផ្តល់ប្រាក់ឈ្នួលមិនស្មើគ្នា ចំពោះការងារដែលមានលក្ខខណ្ឌដូចគ្នា និងផលដែលស្មើគ្នា (មាត្រា ១០៦) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |

| ល.រ | បរិយាយ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល) | ការពិន័យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ការពិន័យអនុលោមតាមការសម្រេចរបស់សាលាដំបូងឬតុលាការ | |
|---|---|---|---|---|---|---|
| | | | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) |
| | | 1 | 2 | 3 = 1 x 2 | 4 | 5 = 1 x 4 |
| 30 | មិនជូនដំណឹងដល់កម្មករនិយោជិតអំពីលក្ខខណ្ឌប្រាក់ឈ្នួល និងរយៈពេលបើកប្រាក់ឈ្នួល (មាត្រា ១១២) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 31 | មិនបើកប្រាក់ឈ្នួលដោយផ្ទាល់ដៃ ឬបើកប្រាក់ឈ្នួលតាមវិធីផ្សេងដោយគ្មានការយល់ព្រមពីកម្មករនិយោជិត (មាត្រា ១១៣) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 32 | បន្ថយសេរីភាពកម្មករនិយោជិត ក្នុងការប្រើប្រាស់ប្រាក់ឈ្នួលរបស់ខ្លួន (មាត្រា ១១៤) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 33 | បើកប្រាក់ឈ្នួលជូនកម្មករនិយោជិតមិនបានត្រឹមត្រូវ ឬធ្វើនៅទីកន្លែងហាមឃាត់ ឬពេលវេលាមិនសមស្រប (មាត្រា ១១៥) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 34 | បើកប្រាក់ឈ្នួលជូនកម្មករនិយោជិតហួសរយៈពេលកំណត់ ឬមិនគោរពតាមចំនួនលើកដែលបានកំណត់ (មាត្រា ១១៦) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 35 | ការកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ក្នុងគោលបំណងឱ្យអ្នកទទួលរកការឱ្យធ្វើដោយចំពោះ ឬមិនចំពោះ (មាត្រា ១២៦) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 36 | ការកាត់ប្រាក់ឈ្នួលទូទាត់សំណង ប៉ះពាល់ដល់បរិមាណភាគជាចំបាច់សម្រាប់ការចិញ្ចឹមជីវិតនៃកម្មករនិយោជិត និងគ្រួសារ (មាត្រា ១២៧) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 37 | ការកាត់ទុកប្រាក់ឈ្នួល និងប្រាក់ឈ្នួលខុសនីតិវិធីកំណត់ (មាត្រា ១២៨) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |

| ល.រ | បរិយាយ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល) | ការពិន័យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ការពិន័យតាមរយៈការផ្តន្ទាទោសរបស់តុលាការ ប្រះអ្នក | |
|---|---|---|---|---|---|---|
| | | | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) |
| | | 1 | 2 | 3 = 1 x 2 | 4 | 5 = 1 x 4 |
| 38 | ការដកហូត ឬការកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ខុសពីគោលការណ៍ច្បាប់ (មាត្រា ១២៩) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 39 | មិនបានត្រួតពិនិត្យ និងបើកប្រាក់ធានានុគ្រោះឱ្យបានត្រឹមត្រូវ (មាត្រា ១៣៤) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 40 | តម្រូវឱ្យកម្មករនិយោជិត ធ្វើការលើសចិរវេលាកំណត់ប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ (មាត្រា ១៣៧) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 41 | មិនបានបែងចែកចិរវេលាតាមវគ្គធ្វើការ ឬចែកពេលឱ្យធ្វើការ ប្រចាំថ្ងៃលើសពីពីរវគ្គ (មាត្រា ១៣៨) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 42 | ផ្តល់ប្រាក់ឈ្នួលធ្វើការថែមម៉ោងជូនកម្មករនិយោជិតមិនបានត្រឹមត្រូវ (មាត្រា ១៣៩) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 43 | បង្ខំឱ្យធ្វើការសង ឬកំណត់ចិរវេលាធ្វើការសង ឬការពន្យាចិរវេលាធ្វើការ ខុសពីគោលការណ៍កំណត់ (មាត្រា ១៤០) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 44 | អនុវត្តមិនបានត្រឹមត្រូវតាមចិរវេលាធ្វើការងារដែលបានកំណត់ (មាត្រា ១៤១) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 45 | ការកំណត់ចិរវេលា និងអត្រាប្រាក់ឈ្នួលការងារពេលយប់មិនបានត្រឹមត្រូវ (មាត្រា ១៥៤) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 46 | មិនអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកមួយថ្ងៃបន្តទៀត ក្នុងករណីថ្ងៃបុណ្យដែលត្រូវបានឈប់សម្រាកត្រូវចំលើថ្ងៃអាទិត្យ (មាត្រា ១៦២) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |

| ល.រ | បរិយាយ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល) | ការពិន័យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ការពិន័យតាមរយៈការសម្រេចរបស់សាលាដំបូងព្រះរាជអាជ្ញា | |
|---|---|---|---|---|---|---|
| | | | ចំនួនថ្ងៃ វងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) | ចំនួនថ្ងៃ វងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) |
| | | 1 | 2 | 3 = 1 x 2 | 4 | 5 = 1 x 4 |
| 47 | មិនបានផ្តល់ប្រាក់បំណាច់ស្មើនឹងប្រាក់ឈ្នួល ចំពោះថ្ងៃឈប់សម្រាកបុណ្យ (មាត្រា ១៦៣) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 48 | មិនបានផ្តល់ប្រាក់បំណាច់នៃការងារដែលបានធ្វើក្នុងនិកាលថ្ងៃឈប់បុណ្យបន្ថែមលើប្រាក់ឈ្នួល (មាត្រា ១៦៤) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 49 | មិនបានផ្តល់ការឈប់សម្រាកប្រចាំឆ្នាំ (មាត្រា ១៦៦) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 50 | ទូទាត់ជាប្រាក់ជំនួសឱ្យការមិនឈប់សម្រាកប្រចាំឆ្នាំ (មាត្រា ១៦៧) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 51 | មិនបានផ្តល់ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំមុនថ្ងៃឈប់សម្រាកប្រចាំឆ្នាំ (មាត្រា ១៦៨) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 52 | មិនបានគណនាថ្ងៃឈប់សម្រាកប្រចាំឆ្នាំ (មាត្រា ១៦៩) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 53 | មិនអនុវត្តតាមនីតិវិធីនៃការឈប់សម្រាកប្រចាំឆ្នាំ (មាត្រា ១៧០) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 54 | អនុវត្តមិនត្រឹមត្រូវតាមការកំណត់ប្រភេទការងារ ដែលបង្ករគ្រោះថ្នាក់ ឬលើសកំលាំងសម្រាប់ក្មេងមានអាយុតិចជាង១៨ឆ្នាំ (មាត្រា ១៧៣) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 55 | ជ្រើសរើសអនីតិជនដែលមានអាយុតិចជាង១៨ឆ្នាំ ធ្វើការនៅអណ្តូងរ៉ែ ឬការយករ៉ែ ឬក្រោមដី និងមិនបានអនុវត្តតាមប្រកាស ដែលកំណត់លក្ខខណ្ឌពិសេសនៃការងារ និងការធ្វើការពិនិត្យវេជ្ជជីវៈដល់អនីតិជនដែលធ្វើការក្រោមដី (មាត្រា ១៧៤) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |

| ល.រ | បរិយាយ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល) | ការពិន័យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ការពិន័យអនុលោមតាមការសម្រេចរបស់សាលាឧទ្ធរណ៍ | |
|---|---|---|---|---|---|---|
| | | | ចំនួនថ្ងៃវងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) | ចំនួនថ្ងៃវងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) |
| | | 1 | 2 | 3 = 1 x 2 | 4 | 5 = 1 x 4 |
| 56 | មិនត្រូវផ្តល់ការងារពេលយប់ដល់ក្មេងដែលមានអាយុតិចជាង ១៨ឆ្នាំ (មាត្រា ១៧៥) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 57 | ផ្តល់ការឈប់សម្រាកពេលយប់សម្រាប់ក្មេងមិនបានត្រឹមត្រូវតាមថិរវេលាកំណត់ (មាត្រា ១៧៦) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 58 | ប្រើប្រាស់កម្មករនិយោជិតវ័យក្មេងមិនបានត្រឹមត្រូវទៅតាមការកំណត់ (មាត្រា ១៧៧) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 59 | ប្រើប្រាស់កម្មករនិយោជិតវ័យក្មេងឱ្យធ្វើការងារលើសកម្លាំង (មាត្រា ១៧៨) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 60 | មិនមានសៀវភៅបញ្ជីចុះនាមក្មេងអាយុតិចជាង ១៨ឆ្នាំ (មាត្រា ១៧៩) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 61 | មិនមានសៀវភៅបញ្ជីចុះនាមក្មេងអាយុតិចជាង ១៨ឆ្នាំ (មាត្រា ១៨០) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 62 | អនុវត្តមិនត្រឹមត្រូវចំពោះការឈប់សម្រាលកូន (មាត្រា ១៨២) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 63 | មិនផ្តល់ពេលវេលាឱ្យបំបៅកូនក្នុងពេលម៉ោងធ្វើការ (មាត្រា ១៨៤) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 64 | គ្មានបន្ទប់បំបៅកូន និងទារកដ្ឋាន (មាត្រា ១៨៧) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 65 | មិនកំណត់ថិរវេលាធ្វើការសម្រាប់ការងារចំការឱ្យបានត្រឹមត្រូវ (មាត្រា ១៩៤) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 66 | ធ្វើឱ្យកម្មករនិយោជិត ទទួលយកភាគឈ្នួលជាវត្ថុ (មាត្រា ១៩៨) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 67 | មិន[illegible]របស់កម្មករនិយោជិត ដែលធ្វើការទៀងទាត់ក្នុងចំការ (មាត្រា ២០០) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |

| ល.រ | បរិយាយ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល) | ការពិន័យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ការពិន័យអនុលោមតាម ការសម្រេចរបស់សាលាជម្រះក្តី | |
|---|---|---|---|---|---|---|
| | | | ចំនួនថ្ងៃវងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) | ចំនួនថ្ងៃវងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) |
| | | 1 | 2 | 3 = 1 x 2 | 4 | 5 = 1 x 4 |
| 68 | គ្មានគេហដ្ឋានសម្រាប់កម្មករនិយោជិតដែលធ្វើការក្នុងចំការ (មាត្រា ២០៤) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 69 | ផ្តល់គេហដ្ឋានមានទំហំតូចជាងទំហំអប្បបរមាសម្រាប់កម្មករនិយោជិត ដែលធ្វើការក្នុងចំការ (មាត្រា ២០៥) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 70 | ការសង់គេហដ្ឋានមិនត្រឹមត្រូវតាមបទបញ្ញាអនាម័យ និងសុខភាពសាធារណៈដែលបានកំណត់ (មាត្រា ២០៦) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 71 | មិនផ្តល់ទឹកឱ្យប្រើប្រាស់តាមតម្រូវការជូនកម្មករនិយោជិត ដែលធ្វើការងារចំការ (មាត្រាទី២១០) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 72 | ធ្វើបង្គន់អនាម័យមានចំនួនមិនសមស្រប និងមិនត្រឹមត្រូវតាមបទដ្ឋានដែលបានកំណត់ (មាត្រា ២១៤) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 73 | គ្មានសាលាបឋមសិក្សាសម្រាប់ក្មេងរៀនតាមអត្រាកំណត់ "ការងារចំការ" (មាត្រា ២២២) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 74 | ពុំបានអនុវត្តតាមលក្ខខណ្ឌអនាម័យ និងសន្តិសុខរបស់កម្មករនិយោជិត ដែលកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (មាត្រា ២២៩, ២៣០ និង២៣១) | 40 000 | 84 | 3 360 000 | ពី 30 ដល់ 120 | ពី 1 200 000 ដល់ 4 800 000 |
| 75 | គ្មានគិលានដ្ឋាន និងក្រុមពេទ្យការងារសម្រាប់ការព្យាបាលបឋម និងការពិនិត្យកាយសម្បទា នៃបុគ្គលិកថ្មី ឬជ្រើសរើសយកឱ្យធ្វើការឡើងវិញ (មាត្រា ២៤០, ២៤១, ២៤២, ២៤៣, ២៤៤, ២៤៥, ២៤៦ និង២៤៧) | 40 000 | 252 | 10 080 000 | ពី 120 ដល់ 360 | ពី 4 800 000 ដល់ 14 400 000 |

| ល.រ | បរិយាយ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល) | ការពិន័យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ការពិន័យអនុលោមតាម ការសម្រុះសម្រួលរបស់សាលាជម្រះក្តី | |
|---|---|---|---|---|---|---|
| | | | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) |
| | | 1 | 2 | 3 = 1 x 2 | 4 | 5 = 1 x 4 |
| 76 | មិនទទួលខុសត្រូវលើគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត (មាត្រា ២៤៩) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 77 | មិនផ្តល់ ឬផ្តល់យឺតយ៉ាវនូវប្រាក់បំណាច់ ឬប្រាក់បំណាច់បន្ថែមជូនកម្មករនិយោជិត ដែលមានគ្រោះថ្នាក់ស្លាប់ ឬបាត់បង់សមត្ថភាពពលកម្មជាអចិន្ត្រៃយ៍ (មាត្រា ២៥៣) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 78 | មិនអនុវត្តតាមការព្រមព្រៀងរវាងគូភាគីក្នុងករណីអ្នករងគ្រោះថ្នាក់ការងារអាចនឹងទទួលបានផលប្រយោជន៍ប្រសើរជាង (មាត្រា ២៥៥) | 40 000 | 21 | 840 000 | ពី 10 ដល់ 30 | ពី 400 000 ដល់ 1 200 000 |
| 79 | បុគ្គលិកនៅការិយាល័យរកការងារឱ្យធ្វើ តម្រូវឱ្យអ្នកសុំការងារធ្វើបង់កម្រៃ (មាត្រា ២៦០) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 80 | គ្មានលិខិតអនុញ្ញាតិប្រើប្រាស់ហត្ថពលកម្មជនបរទេស (មាត្រាទី២៦៤) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 81 | ការបំបិទសិទ្ធិបង្កើតអង្គការវិជ្ជាជីវៈ និងការបង្កើតសហជីព ឬសមាគមទាំងឡាយដែលរួមបញ្ចូលនិយោជក និងកម្មករនិយោជិតនៅក្នុងសហជីព ឬសមាគមតែមួយជាមួយគ្នា (មាត្រាទី២៦៦) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 82 | រាំងរា ឬហាមឃាត់ចំពោះការបង្កើតសហជីពកម្មករនិយោជិត ឬសមាគមនិយោជក និងការតាក់តែងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរដ្ឋបាល, ការបោះឆ្នោតជ្រើសរើសតំណាងដោយសេរី និងការរៀបចំកម្មវិធីការងាររបស់ខ្លួន (មាត្រា ២៦៧) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |

| ល.រ | បរិយាយ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល) | ការពិន័យដោយគ្រូសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ការពិន័យផ្ដល់ដោយតាមការសម្រេចរបស់សាលាឧទ្ធរណ៍ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) | ចំនួនថ្ងៃរងការពិន័យ | | | | | ទឹកប្រាក់ត្រូវពិន័យ (រៀល) | | | | |
| | | 1 | 2 | 3 = 1 x 2 | 4 | | | | | 5 = 1 x 4 | | | | |
| 83 | អង្គការវិជ្ជាជីវៈដែលបានចុះបញ្ជិការួចហើយ មិនបានចម្លងលក្ខន្តិកៈ និងបញ្ជីរាយនាមអ្នកទទួលខុសត្រូវដឹកនាំ និងកិច្ចការរដ្ឋបាលជូនទៅអធិការដ្ឋានការងារ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ (មាត្រាទី២៦៨) | 40 000 | 84 | 3 360 000 | ពី | 61 | ដល់ | 120 | | ពី | 2 440 000 | ដល់ | 4 800 000 | |
| 84 | ការកំណត់លក្ខខណ្ឌរបស់ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈមិនត្រឹមត្រូវ (មាត្រាទី២៦៩) | 40 000 | 84 | 3 360 000 | ពី | 61 | ដល់ | 120 | | ពី | 2 440 000 | ដល់ | 4 800 000 | |
| 85 | ការកំណត់លក្ខខណ្ឌរបស់ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈជាជនបរទេសមិនត្រឹមត្រូវ (មាត្រាទី២៧០) | 40 000 | 84 | 3 360 000 | ពី | 61 | ដល់ | 120 | | ពី | 2 440 000 | ដល់ | 4 800 000 | |
| 86 | រារាំងបំបិទសិទ្ធិសេរីភាពក្នុងការចូលរួម ឬដកខ្លួនចេញពីអង្គការវិជ្ជាជីវៈ (មាត្រា ២៧៣) | 40 000 | 63 | 2 520 000 | ពី | 61 | ដល់ | 90 | | ពី | 2 440 000 | ដល់ | 3 600 000 | |
| 87 | មិនបានចាត់តាំងប្រតិភូសហជីព (មាត្រា ២៧៨) | 40 000 | 63 | 2 520 000 | ពី | 61 | ដល់ | 90 | | ពី | 2 440 000 | ដល់ | 3 600 000 | |
| 88 | និយោជកយកការចូលរួមជាសមាជិករបស់សហជីព ឬការចូលរួមក្នុងសកម្មភាពរបស់សហជីព ដើម្បីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសឱ្យចូលធ្វើការងារ ការដឹកនាំនិងការបែងចែកការងារ... និងការបណ្តេញចេញ (មាត្រា ២៧៩) | 40 000 | 63 | 2 520 000 | ពី | 61 | ដល់ | 90 | | ពី | 2 440 000 | ដល់ | 3 600 000 | |
| 89 | និយោជកប្រព្រឹត្តអំពើរើសអើងជ្រៀតជ្រែកលើសហជីពកម្មករនិយោជិត (មាត្រា ២៨០) | 40 000 | 63 | 2 520 000 | ពី | 61 | ដល់ | 90 | | ពី | 2 440 000 | ដល់ | 3 600 000 | |
| 90 | និយោជកកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានសហជីព ឬបង់ប្រាក់ភាគទានជំនួសកម្មករនិយោជិត (មាត្រា ២៨១) | 40 000 | 63 | 2 520 000 | ពី | 61 | ដល់ | 90 | | ពី | 2 440 000 | ដល់ | 3 600 000 | |

| ល.រ | បរិយាយ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល) | ការពិន័យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ការពិន័យតាមការសម្រេចរបស់សាលាដំបូង ... | |
|---|---|---|---|---|---|---|
| | | | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) |
| | | 1 | 2 | 3 = 1 x 2 | 4 | 5 = 1 x 4 |
| 91 | មិនបានផ្តល់សិទ្ធិប្រយោជន៍ជូនប្រតិភូសហជីព ឬអតីតប្រតិភូសហជីព ដែលបានចាកចេញពីតំណែង ឬផ្លាស់ប្តូរមុខងារ (មាត្រា ២៨២) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 92 | មិនបានបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ឬការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកមិនបានប្រព្រឹត្តទៅតាមនីតិវិធីកំណត់ (មាត្រា ២៨៣) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 93 | ជំទាស់សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោតប្រតិភូបុគ្គលិក (មាត្រា ២៨៦) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 94 | ការរៀបចំជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយមិនត្រឹមត្រូវ តាមនីតិវិធីកំណត់ (មាត្រាទី២៨៧) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 95 | មិនទទួលស្គាល់ប្រតិភូជំនួយដែលមានលក្ខណសម្បត្តិជំនួសឱ្យប្រតិភូពេញសិទ្ធិដែលឈប់ពីមុខងារ ឬអវត្តមានមួយរយៈពេល (មាត្រា ២៩១) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 96 | មិនបានរៀបចំការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកអាណត្តិបន្ត (មាត្រា ២៩២) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 97 | និយោជកមិនបានធ្វើកំណត់ហេតុបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកជូនទៅអធិការដ្ឋានការងារក្នុងរយៈពេលប្រាំបីថ្ងៃ បន្ទាប់ពីការបោះឆ្នោត និងមិនបានបិទកំណត់ហេតុ ដើម្បីផ្សព្វផ្សាយដំណឹងក្នុងសហគ្រាស (មាត្រា ២៩៦) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 98 | មិនបានចូលរួមផ្សះផ្សាវិវាទការងាររួម (មាត្រា ៣០៦) | 40 000 | 42 | 1 680 000 | ពី 31 ដល់ 60 | ពី 1 240 000 ដល់ 2 400 000 |
| 99 | មិនធានាការពារសេរីភាពរបស់កម្មករនិយោជិតដែលមិនមែនជាកូដករ (មាត្រា ៣៣១) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |

| ល.រ | បរិយាយ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល) | ការពិន័យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ការពិន័យអនុលោមតាមការសម្រេចរបស់សាលាជម្រះក្តី | |
|---|---|---|---|---|---|---|
| | | | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) | ចំនួនថ្ងៃរងការពិន័យ | ទឹកប្រាក់ត្រូវពិន័យ (រៀល) |
| | | 1 | 2 | 3 = 1 x 2 | 4 | 5 = 1 x 4 |
| 100 | ការដាក់ទណ្ឌកម្មចំពោះកូដករ (មាត្រា ៣៣៣) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 101 | ការជ្រើសរើសកម្មករនិយោជិតផ្សេងមកជំនួសកូដករក្នុងអំឡុងពេលធ្វើកូដកម្ម (មាត្រា ៣៣៤) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 102 | ឡុកអោមិនស្របតាមនីតិវិធី (មាត្រា ៣៣៥) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 103 | ប្រើប្រាស់ហត្ថពលកម្មបរទេសគ្មានសៀវភៅការងារ (មាត្រាទី៣៧២) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 104 | អ្នកដឹកនាំ ឬអភិបាលនៃអង្គការវិជ្ជាជីវៈ ដែលនាំអង្គការទាំងនោះឱ្យធ្វើសកម្មភាពផ្ទុយពីគោលដៅ (មាត្រា ៣៧៨) | 40 000 | 63 | 2 520 000 | ពី 61 ដល់ 90 | ពី 2 440 000 ដល់ 3 600 000 |
| 105 | ជនដែលជំទាស់ ឬប៉ុនប៉ងជំទាស់នឹងការអនុវត្តតាមមុខងារ ឬការប្រើប្រាស់អំណាចដែលច្បាប់ផ្តល់ឱ្យអធិការការងារ ឬអភិបាលការងារព្រមទាំងអធិការពេទ្យការងារ (មាត្រា ៣៨២) | 40 000 | 252 | 10 080 000 | ពី 120 ដល់ 360 | ពី 4 800 000 ដល់ 14 400 000 |